# សេចក្តីណែនាំឆ្នាំ 2019-20

# ឥណទានឥតសំណងដែលសមស្របទៅនឹងសហគមន៍ដែលគ្មានកាកសំណល់

## ពាក្យស្នើសុំ ផុតកំណត់នៅត្រឹមម៉ោង 5:00 ល្ងាច ថ្ងៃទី 22 ខែមីនា ឆ្នាំ 2019

បច្ចុប្បន្ននេះ ផ្នែកសេវាសាធារណៈទីក្រុង Seattle (SPU) កំពុងទទួលយកពាក្យស្នើសុំឥណទានឥតសំណងសម្រាប់គម្រោងសហគមន៍ដែលផ្តោតលើការបង្ការកុំឲ្យមានសំរាម។ ការបង្ការកុំឲ្យមានសំរាម មានន័យថាជាការបង្កើតសំរាមឲ្យមានចំនួនតិច តាមរយៈការទិញ និងការប្រើប្រាស់តិចតួច ការប្រើប្រាស់របស់ដែលអាចប្រើប្រាស់បានសារជាថ្មី និងការចែករំលែក និងការផ្តល់សម្ភារៈនានា ដើម្បីឲ្យអ្នកដទៃអាចប្រើប្រាស់សម្ភារៈទាំងនោះបានផងដែរ។ នៅពេលដែលយើងបង្ការមិនឲ្យមានសំរាម យើងជួយដល់បរិស្ថាន ការពារសុខភាពសាធារណៈ កសាងសហគមន៍ និងសន្សំសំចៃប្រាក់កាស។

គោលបំណងនៃកម្មវិធីឥណទានឥតសំណង៖

- គាំទ្រដល់ភាពជាអ្នកដឹកនាំនិងការច្នៃប្រឌិតរបស់សហគមន៍ជុំវិញបញ្ហាការបង្ការកុំឲ្យមានសំរាម
- បង្កើនការផ្តល់ជូនឱកាសស្តីពីការបង្ការមិនឲ្យមានសំរាមដល់សមាគមន៍
- កាត់បន្ថយចំនួនសម្ភារៈដែលនឹងក្លាយជាសំរាមនៅក្នុងទីក្រុង Seattle

ការផ្តល់មូលនិធិ៖

- មានទឹកប្រាក់មូលនិធិសរុបចំនួន $100,000 ដែលត្រូវផ្តល់ជូនសម្រាប់វគ្គឥណទានឥតសំណងឆ្នាំ 2019-20។
- សំណើសុំឥណទានឥតសំណង អាចមានចំនួនពី $5,000 ទៅ $20,000។ SPU រក្សាសិទ្ធិក្នុងការផ្តល់ប្រាក់ឥណទានតិចជាង ឬច្រើនជាងនេះ។
- ការផ្តល់ប្រាក់ឧបត្ថម្ភ ត្រូវបានធ្វើឡើងផ្អែកលើមូលដ្ឋាននៃការទូទាត់ប្រាក់សំណង។
- ប្រាក់មូលនិធិឥណទានឥតសំណង ត្រូវតែប្រើប្រាស់ក្នុងរយៈពេល 12 ខែ បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមគម្រោង។ ឥណទានឥតសំណង មិនមានផ្តល់ជូនប្រាក់ឧបត្ថម្ភជាបន្តបន្ទាប់សម្រាប់គម្រោងនានានោះទេ។

## តើនរណាគួរដាក់ពាក្យស្នើសុំ

SPU លើកទឹកចិត្តឲ្យមានការដាក់ពាក្យសុំពី៖

- អង្គការមិនរកប្រាក់ចំណូល
- សហគមន៍ និងក្រុមក្នុងសហគមន៍ជិតខាង
- អាជីវកម្ម
- សាលារៀន មហាវិទ្យាល័យ និងសាកលវិទ្យាល័យ
- ស្ថាប័ន (ដូចការថែទាំសុខភាព ឬកម្មវិធីផ្ទះជួល)
- អង្គការធ្វើការលើមូលដ្ឋានជំនឿ
- កម្មវិធីសម្រាប់យុវជននិងកុមារ

អ្នកដាក់ពាក្យសុំអាចដាក់ពាក្យសុំលើសពីមួយ ប៉ុន្តែមានសិទ្ធិទទួលបានការផ្តល់ថវិកាតែមួយប៉ុណ្ណោះ។

អ្នកដាក់ពាក្យស្នើសុំ ត្រូវមានអាជ្ញាប័ណ្ណអាជីវកម្មរដ្ឋវ៉ាស៊ីនតោន និងអាជ្ញាប័ណ្ណទីក្រុង Seattle ដើម្បីទទួលបានមូលនិធិឥណទានឥតសំណង ឬធ្វើការតាមរយៈភ្នាក់ងារពន្ធដែលមានអាជ្ញាប័ណ្ណដូចដែលបានតម្រូវនេះ។ ភ្នាក់ងារពន្ធ មានទំនួលខុសត្រូវក្នុងការទទួលនិងគ្រប់គ្រងមូលនិធិឥណទានឥតសំណងសម្រាប់គម្រោងរបស់អ្នក។ ភ្នាក់ងារពន្ធ អាចគិតថ្លៃសេវារហូតដល់ 10% នៃឥណទានឥតសំណងដែលទទួលបាន ដែលអាចធ្វើការទូទាត់បានតាមរយៈប្រាក់ឥណទានឥតសំណង។

**ព័ត៌មានអាជ្ញាប័ណ្ណអាជីវកម្មក្រុងស៊ីថល៖** https://www.seattle.gov/licenses/get-a-business-license/cost-of-a-business-license។ **ព័ត៌មានអាជ្ញាប័ណ្ណអាជីវកម្មរដ្ឋវ៉ាស៊ីនតោន៖** http://bls.dor.wa.gov/faqlicense.aspx

## ការដាក់ពាក្យសុំឡើងវិញ

អ្នកដាក់ពាក្យសុំអាចដាក់ពាក្យសុំជំនួយថវិកាឡើងវិញនៅរៀងរាល់ខួបផ្តល់មូលនិធិនីមួយៗតាមរយៈ៖

- ការដាក់ពាក្យសុំឡើងវិញសម្រាប់គម្រោងដែលមិនទាន់ទទួលបានមូលនិធិ។ យើងសូមណែនាំឲ្យអ្នកទាក់ទងមកយើងដើម្បីស្វែងយល់ពីរបៀបដែលអ្នកអាចធ្វើឲ្យពាក្យសុំរបស់អ្នកប្រសើរឡើងសម្រាប់ខួបផ្តល់មូលនិធិលើកក្រោយ។
- ការដាក់ពាក្យសុំសម្រាប់គម្រោងថ្មី។

- ការដាក់ពាក្យសុំពង្រីកគម្រោង ឬអនុវត្តដំណាក់កាលបន្ទាប់។ ពាក្យសុំត្រូវបង្ហាញពីការទប់ស្កាត់កាកសំណល់ដែលកើនឡើង។ មូលនិធិជំនួយថវិកាមិនអាចត្រូវបានប្រើដើម្បី*ទ្រទ្រង់*គម្រោងនៅត្រឹមកម្រិតទប់ស្កាត់កាកសំណល់ដែលមានស្រាប់នោះទេ។

## លក្ខខណ្ឌតម្រូវនៃគម្រោង

គម្រោងនានា ត្រូវបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យទាំងបីដើម្បីដាក់ពាក្យសុំ៖

1. គម្រោងនានាត្រូវធ្វើឡើងនៅក្នុងដែនកំណត់នៃទីក្រុង Seattle ឬត្រូវមានឥទ្ធិពលដោយផ្ទាល់ទៅលើសំរាមនៅក្នុងទីក្រុង Seattle។ អ្នកដាក់ពាក្យសុំអាចស្ថិតនៅក្រៅក្រុងស៊ីថល ប្រសិនបើគម្រោងនេះផ្ដោតលើក្រុងស៊ីថល។

   សូមមើលកំណែប្រែផែនទីខ្នាតធំនៃដែនកំណត់របស់ទីក្រុង Seattle តាមអនឡាញ៖
   http://clerk.ci.seattle.wa.us/~public/nmaps/fullcity.htm




2. គម្រោងនានាត្រូវផ្ដោតជាសំខាន់លើការបង្ការកុំឲ្យមានសំរាម។ ឧទាហរណ៍នានារួមមាន៖
   - ការអប់រំសហគមន៍ស្ដីពីរបៀបបង្ការមិនឲ្យមានសំរាម
   - ការកាត់បន្ថយការប្រើប្លាស្ទិចតែម្ដងលើក ដូចជាការលើកកម្ពស់ការប្រើប្រាស់ប្រអប់ដាក់ភេសជ្ជៈ និងម្ហូបអាហារដែលប្រើបានយូរ
   - ការរៀបចំសិក្ខាសាលាដើម្បីជួយដល់ប្រជាជនក្នុងការជួសជុលរបស់របរដែលខូចបាក់បែក
   - ការធ្វើតេស្ដយុទ្ធសាស្ត្រថ្មី ដើម្បីធ្វើឲ្យមានសំណល់អាហារតិចនៅក្នុងភោជនីយដ្ឋាន
   - ការបង្កើតកម្មវិធី ដើម្បីជួបប្រជាជនចែករំលែកនូវចំណីអាហារ និងរបស់របរផ្សេងទៀត
   - ការចែករំលែកឧបករណ៍ជារបស់រួម ជាជាងឲ្យមនុស្សទិញរបស់នោះប្រើប្រាស់រៀងៗខ្លួន
   - ការបរិច្ចាគចំណីអាហារ សម្លៀកបំពាក់ ឬរបស់របរផ្សេងទៀត ដើម្បីឲ្យអ្នកដទៃផ្សេងទៀតអាចប្រើប្រាស់របស់ទាំងនោះបាន
   - ការកែច្នៃចំណីអាហារនិងកាកសំណល់នៅសាលារៀនឲ្យទៅជាជីកំប៉ុស្ដ ដើម្បីប្រើប្រាស់នៅក្នុងសាលារៀន ឬសួនដំណាំសហគមន៍
   - គំនិតផ្ដួចផ្ដើមផ្សេងទៀតដែលអ្នកមានសម្រាប់បង្ការកុំឲ្យមានសំរាម!

   ឥណទានឥតសំណង<u>មិន</u> ផ្ដល់មូលនិធិដល់គម្រោងដែលផ្ដោតលើ៖
   - ការកែច្នៃប្រើប្រាស់ឡើងវិញ
   - ការធ្វើកំប៉ុស្ដនៅក្រៅទីតាំង (កែច្នៃនិងលក់ទៅកន្លែងផ្សេង)
   - ការជួលកង់ និងរថយន្តរយៈពេលខ្លី

3. គម្រោងនានាត្រូវមានលក្ខណៈពិសេស<u>មួយឬច្រើនយ៉ាង</u> ដូចមានរៀបរាប់នៅផ្នែកខាងក្រោម៖
   - **ត្រូវមានការច្នៃប្រឌិត៖** ធ្វើតេស្ដ ឬពង្រីកលើវិធីសាស្ត្រថ្មីៗ ឬបច្ចេកវិទ្យាថ្មី ដូចជាការបង្កើតកម្មវិធី ឬដឹកនាំឲ្យមានការបង្កើតរោងជាងជួសជុលនៅក្នុងទីក្រុង Seattle

     **និង/ឬ**
   - **ចូលរួមជាមួយសហគមន៍មួយឬច្រើនដូចខាងក្រោម៖** សហគមន៍ជនមិនមានស្បែកស សហគមន៍ជនអន្តោប្រវេសន៍ សហគមន៍ជនភៀសខ្លួន សហគមន៍សម្រាប់អ្នកមានប្រាក់ចំណូលកម្រិតទាប សហគមន៍ជនពិការ សហគមន៍មនុស្សចាស់ សហគមន៍មនុស្សពេញវ័យ សហគមន៍យុវជន សហគមន៍កុមារ និង/ឬ អាជីវកម្មខាតតូច

     **និង/ឬ**
   - **ជួយសហគមន៍ដែលកំពុងត្រូវការជំនួយ៖** ដូចជាការបង្កើនលទ្ធភាពប្រើប្រាស់តាមរយៈការផ្ដល់ធនធានដោយឥតគិតថ្លៃ ឬតម្លៃទាប ឬការបណ្ដុះបណ្ដាលការងារដល់សហគមន៍អ្នកគ្មានផ្ទះសម្បែង ឬមានប្រាក់ចំណូលទាប

# លក្ខខណ្ឌតម្រូវនានានៃមូលនិធិ និងមូលនិធិបន្ទុី

**ការផ្តល់មូលនិធិ៖**

- មានទឹកប្រាក់មូលនិធិសរុបចំនួន $100,000 ដែលត្រូវផ្តល់ជូនសម្រាប់វដ្តឥណទានឥតសំណងឆ្នាំ 2019-20។
- សំណើសុំឥណទានឥតសំណង អាចមានចំនួនពី $5,000 ទៅ $20,000។ SPU រក្សាសិទ្ធិក្នុងការផ្តល់ប្រាក់ឥណទានតិចជាង ឬច្រើនជាងនេះ។
- ការផ្តល់ជំនួយថវិកាអាចទាបជាងចំនួនទឹកប្រាក់ដែលបានស្នើសុំ អាស្រ័យលើឆន្ទានុសិទ្ធិរបស់គណៈកម្មាធិការត្រួតពិនិត្យ និង SPU
- មូលនិធិឥណទានឥតសំណងនឹងត្រូវបង់ផ្អែកលើមូលដ្ឋាននៃការទូទាត់ប្រាក់សំណង។ ប្រសិនបើថ្លៃចំណាយចុងក្រោយនៃគម្រោងដែលបានបញ្ចប់ គឺតិចជាងកញ្ចប់ថវិកា ការផ្តល់ប្រាក់ឧបត្ថម្ភនេះនឹងត្រូវកាត់បន្ថយ។
- ប្រាក់មូលនិធិឥណទានឥតសំណង ត្រូវតែប្រើប្រាស់ក្នុងរយៈពេល 12 ខែ បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមគម្រោង។ ប្រាក់ឧបត្ថម្ភនេះ មិនបានផ្តល់មូលនិធិរយៈពេលវែងសម្រាប់គម្រោងនានានោះទេ។ អ្នកដាក់ពាក្យសុំ អាចធ្វើការស្នើសុំឡើងវិញជាប្រចាំឆ្នាំ សម្រាប់គម្រោងថ្មី ឬគម្រោងដែលបានពង្រីកបន្ថែម។

**លក្ខខណ្ឌតម្រូវនៃមូលនិធិបន្ទុី៖**

- មូលនិធិបន្ទុី ត្រូវតែមានចំនួនពាក់កណ្តាលនៃប្រាក់មូលនិធីដែលបានស្នើឡើង (តម្លៃ 50 កាក់សម្រាប់រាល់ចំនួនទឹកប្រាក់១ដុលាដែលបានផ្តល់ជូនតាមរយៈសាលាក្រុង)។
- អ្នកដាក់ពាក្យស្នើសុំ ត្រូវរៀបចំឯកសារប្រាក់មូលនិធិបន្ទុីដើម្បីទទួលបានឥណទាន។
- ប្រាក់វិភាគទានបន្ទុី អាចជាសម្ភារៈសេវាកម្ម ឬជាសាច់ប្រាក់។
- ធនធានទីក្រុង Seattle ដូចជាម៉ោងបុគ្គលិកទីក្រុង ការប្រើប្រាស់បរិក្ខារទីក្រុង និង/ឬប្រាក់ឧបត្ថម្ភទីក្រុង អាចមិនត្រូវបានរាប់បញ្ចូលជាផ្នែកមួយនៃមូលនិធិបន្ទុីនោះទេ។

**លក្ខខណ្ឌទាមទារចំពោះការធានារ៉ាប់រង៖**

ជាទូទៅ គម្រោងនឹងត្រូវការការធានារ៉ាប់រងដូចខាងក្រោម៖

- $1,000,000 នៅក្នុងការធានារ៉ាប់រងលើការទទួលខុសត្រូវទូទៅផ្នែកពាណិជ្ជកម្ម (CGL)
- $1,000,000 នៅក្នុងការធានារ៉ាប់រងលើការទទួលខុសត្រូវផ្នែកយានយន្តពាណិជ្ជកម្ម។ ការធានារ៉ាប់រងគឺសម្រាប់តែទៅលើការប្រើប្រាស់យានជំនិះពាណិជ្ជកម្ម មិនមែនជាការធានារ៉ាប់រងលើយានជំនិះផ្ទាល់ខ្លួនទេ។ លក្ខខណ្ឌទាមទារនេះអាចត្រូវបានលើកលែង ប្រសិនបើគម្រោងមិនពាក់ព័ន្ធនឹងការប្រើយានជំនិះ ឬប្រសិនបើគម្រោងនេះប្រើប្រាស់តែសេវាកម្មបញ្ញើ ឬការដឹកជញ្ជូនដែលមានអាជ្ញាប័ណ្ណ និងមានការធានារ៉ាប់រងផ្នែកពាណិជ្ជកម្មរួចហើយ។
- ការធានារ៉ាប់រងលើសំណងកម្មករ

លក្ខខណ្ឌទាមទារចំពោះការធានារ៉ាប់រងជាក់លាក់នឹងប្រែប្រួលតាមគម្រោងនីមួយៗ។ SPU នឹងធ្វើការជាមួយគម្រោងដែលត្រូវបានជ្រើសរើសផ្តល់ជំនួយថវិកា ដើម្បីកំណត់អំពីលក្ខខណ្ឌទាមទារចំពោះការធានារ៉ាប់រង។ ការធានារ៉ាប់រងជាក់លាក់ចំពោះគម្រោងមានតម្លៃខ្ពស់ជាងការធានារ៉ាប់រងធម្មតារបស់អ្នក គឺអាចរួមបញ្ចូលនៅក្នុងសំណើសុំជំនួយថវិការបស់អ្នក ដោយច្រើនបំផុតត្រឹម $500 ដែលអាចទទួលបានតាមរយៈជំនួយថវិកា។

**ប្រភេទនៃការចំណាយ៖**

ការចំណាយនានាដែលទូទាត់សំណងបានវិញ និងវិភាគទានបន្ទុី ត្រូវមានការជាប់ទាក់ទងដោយផ្ទាល់ទៅនឹងគម្រោងនេះ។

- វិភាគទានបន្ទុី អាចចាប់ផ្តើមនៅត្រឹមថ្ងៃផុតកំណត់ការដាក់ពាក្យស្នើសុំ។
- ចំណាយលើការទូទាត់សំណង អាចចាប់ផ្តើមនៅពេលដែលមានការចុះកិច្ចសន្យាជាមួយនឹងសាលាក្រុងស៊ីញ្ញេកុងត្រា។

| | ចំណាយលើការទូទាត់សំណង | មូលនិធិបន្ទុី |
|---|---|---|
| ពេលវេលារបស់បុគ្គលិកចំពោះគម្រោងនេះ (អាចរាប់បញ្ចូលទាំងការចំណាយទូទៅ) | ✓ | ✓ |
| បរិក្ខារផ្គត់ផ្គង់ សម្ភារៈ និងឧបករណ៍គម្រោង | ✓ | ✓ |
| សេវាដែលពាក់ព័ន្ធនឹងគម្រោង ដូចជាសេវាបកប្រែ ការបោះពុម្ព និងការរៀបចំគម្រោងជាដើម | ✓ | ✓ |

| | ចំណាយលើការទូទាត់សំណង | មូលនិធិបន្សី |
|---|---|---|
| ការជួលទីតាំងសម្រាប់សកម្មភាពគម្រោង | ✓ | ✓ |
| អាហារ និងភេសជ្ជៈសម្រាប់សកម្មភាពសហគមន៍ពាក់ព័ន្ធនឹងគម្រោង ដោយមិនរាប់បញ្ចូលភេសជ្ជៈមានជាតិអាល់កុល (ចំនួនទឹកប្រាក់សម្រាប់មនុស្សម្នាក់ៗត្រូវមានតម្លៃសមរម្យសម្រាប់គម្រោង ដោយចំនួនអតិបរមាត្រឹម $10 ក្នុងមនុស្សម្នាក់) | ✓ | ✓ |
| ប្រាក់លើកទឹកចិត្តសម្រាប់អ្នកចូលរួមក្នុងគម្រោង (ចំនួនទឹកប្រាក់សម្រាប់មនុស្សម្នាក់ៗត្រូវមានតម្លៃសមរម្យសម្រាប់គម្រោង) | ✓ | ✓ |
| ចំណត និងថ្លៃសាំងពាក់ព័ន្ធនឹងគម្រោងនៅក្នុងទីក្រុង Seattle (ត្រូវបានទូទាត់តាមអត្រាថ្លៃសាំងធ្វើដំណើររបស់សហព័ន្ធ) | ✓ | ✓ |
| ថ្លៃភ្នាក់ងារសារពើពន្ធ (អាចមិនលើសពី 10% នៃប្រាក់ឧបត្ថម្ភគម្រោងសរុបនោះទេ) | ✓ | ✓ |
| ការធានារ៉ាប់រងជាក់លាក់ចំពោះគម្រោងមានតម្លៃខ្ពស់ជាងការធានារ៉ាប់រងធម្មតារបស់អ្នក (ចំនួនទឹកប្រាក់ធានារ៉ាប់រងត្រូវមានតម្លៃសមស្របនឹងលទ្ធផលរបស់គម្រោង ដោយចំនួនអតិបរិមាត្រឹម $500 ដែលអាចទទួលបានតាមរយៈជំនួយថវិកា) | ✓ | ✓ |
| ពេលវេលាអ្នកស្ម័គ្រចិត្តធ្វើការឲ្យគម្រោង (មានតម្លៃ $24/ម៉ោង) | | ✓ |
| ចំណាយលើការធ្វើដំណើរនៅក្រៅទីក្រុងដែលពាក់ព័ន្ធនឹងគម្រោង | | ✓ |
| មូលនិធិគណទានដទៃផ្សេងទៀត ឬវិភាគទានសាច់ប្រាក់ចំពោះគម្រោងនេះ (មិនរួមបញ្ចូលមូលនិធិផ្សេងទៀតពីទីក្រុង Seattle នោះទេ) | | ✓ |

## ដំណើរការពាក្យស្នើសុំ

**តារាងពេលវេលា៖**

| | |
|---|---|
| **ថ្ងៃផុតកំណត់ការដាក់ពាក្យស្នើសុំ** | ថ្ងៃទី 22 ខែមីនា ឆ្នាំ 2019 |
| **សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចចិត្ត** | ឧសភា ឆ្នាំ 2019 |
| **កិច្ចសន្យាជាមួយទីក្រុងដែលបានចុះហត្ថលេខា** | នៅត្រឹមខែសីហា ឆ្នាំ 2019 |
| **ការងារចាប់ផ្តើម** | ខែកក្កដា - តុលាឆ្នាំ 2019 |
| **កិច្ចការបានបញ្ចប់** | ក្នុងរយៈពេល 12 ខែ បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមគម្រោង |

**ជំហាននៃការដាក់ពាក្យស្នើសុំ៖**

**ជំហានទី 1៖ សូមអានគោលការណ៍ណែនាំ**

**ជំហានទី 2៖ ទំនាក់ទំនងមកយើង**

- បញ្ជាក់ថាគម្រោងរបស់អ្នកមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភ
- សាកសួរសំណួរនានាអំពីសេចក្តីណែនាំ និងពាក្យស្នើសុំ

**ជំហានទី 3៖ ចូលរួមវគ្គបណ្តុះបណ្តាលព័ត៌មានស្តីពីគណទានគតសំណង (មិនចាំបាច់)**

| **ក្រុងស៊ីថលខាងជើង** | **ក្រុងស៊ីថលកណ្តាល** | **ក្រុងស៊ីថលខាងត្បូង** | **ក្រុងស៊ីថលខាងលិច** |
|---|---|---|---|
| ថ្ងៃទី 15 ខែមករា ឆ្នាំ 2019 | ថ្ងៃទី 26 ខែមករា ឆ្នាំ 2019 | ថ្ងៃទី 4 ខែកុម្ភៈ ឆ្នាំ 2019 | ថ្ងៃទី 9 ខែកុម្ភៈ ឆ្នាំ 2019 |
| ម៉ោង 5:30-7:00 ល្ងាច | ម៉ោង 12:00-1:30 រសៀល | ម៉ោង 5:30-7:00 ល្ងាច | ម៉ោង 12:00-1:30 រសៀល |
| បណ្ណាល័យ Green Lake | បណ្ណាល័យ Montlake | បណ្ណាល័យ Columbia | បណ្ណាល័យ Delridge |
| 7364 E Green Lake Dr N | 2401 24th Ave E | 4721 Rainier Ave S | 5423 Delridge Way SW |

សូម ស្នើសុំ សេវាបកប្រែភាសា ឬក៏តម្រូវការអ្វីផ្សេងៗ**យ៉ាងហោចណាស់មួយសប្តាហ៍** មុនវគ្គសិក្សាព័ត៌មាន។

**ជំហានទី 4៖ ប្រគល់ពាក្យស្នើសុំគណទានឥតសំណងរបស់អ្នកជាទម្រង់ឯកសារបោះពុម្ព ឬជាទម្រង់វីដេអូ នៅត្រឹមថ្ងៃទី 22 ខែមីនា ឆ្នាំ 2019។**

- ទម្រង់ពាក្យស្នើសុំដែលបានបោះពុម្ព (មិនត្រូវវែងជាង 7 ទំព័រនោះទេ)
- វីដេអូស្ដីពីសេចក្ដីណែនាំគម្រោង (មិនត្រូវលើស 20 នាទីនោះទេ)
- ទម្រង់ពាក្យស្នើសុំកញ្ចប់ថវិកា (សម្រាប់ពាក្យសុំជាឯកសារបោះពុម្ព និងវីដេអូ)

ពាក្យស្នើសុំត្រូវប្រគល់ជូនជាភាសាដែលអ្នកចង់បាន។ SPU នឹងផ្ដល់ការបកប្រែឯកសារ/ការបកប្រែផ្ទាល់មាត់។

## ការត្រួតពិនិត្យពាក្យស្នើសុំ

**ក្រុមត្រួតពិនិត្យ៖**
ក្រុមត្រួតពិនិត្យគណទានឥតសំណង គឺរួមមានសមាជិកសហគមន៍ និងបុគ្គលិកទីក្រុង Seattle ដែលមានសាវតាផ្សេងគ្នា និងមានជំនាញខុសៗគ្នា។

**លក្ខខណ្ឌវិនិច្ឆ័យនៃការត្រួតពិនិត្យ៖**
គម្រោងនានានឹងត្រូវបានត្រួតពិនិត្យជាលើកទីមួយដើម្បីប្រាកដថា គម្រោងទាំងអស់នោះបំពេញតាមលក្ខខណ្ឌតម្រូវនានារបស់គម្រោងនេះ។ បន្ទាប់មកទៀត ក្រុមត្រួតពិនិត្យគណទានឥតសំណង នឹងដាក់ពិន្ទុលើគម្រោងដែលទទួលបានសិទ្ធ ទៅតាមលក្ខខណ្ឌវិនិច្ឆ័យនៃការជ្រើសរើសចំនួនប្រាំមួយចំណុច ដូចបានជ្រើសរើស ខាងក្រោម។ SPU នឹងធ្វើការពិចារណាអំពីពិពិធភាពនៃទីតាំងភូមិសាស្ត្រ សហគមន៍ដែលរងការប៉ះពាល់ និងប្រភេទនៃគម្រោង។

1. **(30%) ការបង្ការកុំឲ្យមានសំរាម៖** សក្ដានុពលរបស់គម្រោងក្នុងការបង្ការកុំឲ្យមានសំរាម។
   - តើគម្រោងអាចវាស់ស្ទង់ភាពជោគជ័យបានដែរឬទេ?
   - តើអ្វីទៅជាសក្ដានុពលសម្រាប់ការកាត់បន្ថយដែលអាចគិតជាលេចឬចំនួនផោននៃសម្ភារៈនានាដែលនឹងចូលទៅក្នុងប្រឡាយទឹកស្អុយ?
   - តើអ្វីទៅជាសក្ដានុពលសម្រាប់ការប្រាស្រ័យទាក់ទងជាមួយសហគមន៍ និងមានការផ្លាស់ប្ដូរអាកប្បកិរិយា?
   - តើការបង្ការកុំឲ្យមានសំរាម នឹងមានឥទ្ធិពលលើការបន្តគម្រោងបានយ៉ាងដូចម្ដេច បន្ទាប់ពីគណទានឥតសំណងនេះត្រូវបានបញ្ចប់?
2. **(15%) ការច្នៃប្រឌិត៖** ការប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកវិទ្យាថ្មីៗរបស់គម្រោង។
   - តើគម្រោងនឹងធ្វើតេស្ត ឬពង្រីកលើវិធីសាស្ត្រ ឬបច្ចេកវិទ្យានានាយ៉ាងដូចម្ដេច?
   - តើគម្រោងនេះអាចនឹងធ្វើឡើងសារជាថ្មីដោយអ្នកដទៃផ្សេងទៀតនៅក្នុងសហគមន៍ដែរឬទេ?
   - តើវិធីសាស្ត្រនិងលទ្ធផលគម្រោងអាចចែករំលែកជាមួយសហគមន៍បានយ៉ាងដូចម្ដេច?
3. **(15%) ការចូលរួមរបស់សហគមន៍៖** សក្ដានុពលរបស់គម្រោងក្នុងការឲ្យសហគមន៍ចូលរួមយ៉ាងមានប្រសិទ្ធិភាពពាក់ព័ន្ធនឹងការបង្ការ/ការប្រាស់ឡើងវិញ។
   - តើគម្រោងប្រើប្រាស់យុទ្ធសាស្ត្រចូលរួមដែលមានប្រសិទ្ធិភាពសម្រាប់អ្នកចូលរួមស្ដាប់ដែរឬទេ?
   - តើសហគមន៍ដែលរងការប៉ះពាល់នឹងចូលរួមក្នុងការធ្វើផែនការនិងការអនុវត្តគម្រោងបានយ៉ាងដូចម្ដេច?
   - តើគម្រោងធ្វើការសហការដៃគូជាមួយសហគមន៍យ៉ាងដូចម្ដេច?
   - តើគម្រោងចូលរួមជាមួយសហគមន៍មិនមែនជនជាតិស្បែកស ជនអន្តោប្រវេសន៍ ជនភាសខ្លួន អ្នកមានប្រាក់ចំណូលកម្រិតទាប ជនពិការ មនុស្សចាស់ មនុស្សពេញវ័យវ័យក្មេង យុវជន កុមារ និង/ឬអាជីវកម្មតូចៗយ៉ាងដូចម្ដេច?
4. **(15%) អត្ថប្រយោជន៍សហគមន៍៖** សក្ដានុពលគម្រោងសម្រាប់ការផ្ដល់ជូនអត្ថប្រយោជន៍ដល់សហគមន៍។
   - តើគម្រោងនេះផ្ដល់អត្ថប្រយោជន៍ដល់សហគមន៍យ៉ាងដូចម្ដេច (ដូចជា ការលើកកម្ពស់សុខភាពសាធារណៈ ការផ្ដល់ការងារឬជំនាញការងារ ឬការផ្ដល់ធនធានដោយឥតគិតថ្លៃឬក្នុងតម្លៃទាប)?
   - តើគម្រោងផ្ដល់អត្ថប្រយោជន៍ដល់សហគមន៍ដែលមានតម្រូវការ ដូចជាជនអាណាថា ឬអ្នកមានប្រាក់ចំណូលកម្រិតទាបបានច្រើនប៉ុណ្ណា?
5. **(15%) សមត្ថភាពគម្រោង៖** សក្ដានុពលរបស់គម្រោងក្នុងការសម្រេចបានជោគជ័យផ្អែកលើសមត្ថភាព។
   - តើគម្រោងនេះមានបុគ្គលិក ដៃគូ អ្នកស្ម័គ្រចិត្ត និងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីសម្រេចបានជោគជ័យដែរឬទេ?
   - តើភាពជាដៃគូនានាត្រូវបានពង្រឹងហើយឬនៅ?
   - តើគម្រោងមានចំណេះដឹង ជំនាញ បទពិសោធន៍ និងទំនាក់ទំនង ដើម្បីសម្រេចបានជោគជ័យដែរឬទេ?

6. **(10%) កញ្ចប់ថវិកា៖** សក្តានុពលរបស់គម្រោងក្នុងការសម្រេចបានជោគជ័យផ្អែកលើកញ្ចប់ថវិកាដែលស្នើសុំ។
    - តើកញ្ចប់ថវិកាស្របគ្នាជាមួយនឹងសំណើគម្រោងដែរឬទេ?
    - តើការប៉ាន់តម្លៃកញ្ចប់ថវិកាមានភាពត្រឹមត្រូវច្បាស់លាស់ដែរឬទេ?
    - តើរាល់ការចំណាយទាំងអស់សមស្របទៅនឹងឥណទានឥតសំណងនេះដែរឬទេ?
    - តើចំនួនទឹកប្រាក់ដែលបានស្នើសុំសមស្របសម្រាប់លទ្ធផលរំពឹងទុក ដែរឬទេ?

## ការចុះកិច្ចសន្យា និងការបង់ប្រាក់

**ការចុះកិច្ចសន្យា៖**

- អ្នកដែលទទួលបានការឧបត្ថម្ភ ត្រូវមានអាជ្ញាប័ណ្ណអាជីវកម្មរដ្ឋវ៉ាស៊ីនតោន និងអាជ្ញាប័ណ្ណទីក្រុង Seattle ដើម្បីទទួលបានមូលនិធិឥណទានឥតសំណង ឬធ្វើការតាមរយៈភ្នាក់ងារពន្ធដែលមានអាជ្ញាប័ណ្ណដូចដែលបានតម្រូវនេះ។
- អ្នកដែលទទួលបានការឧបត្ថម្ភ ត្រូវចុះកិច្ចសន្យាជាមួយ SPU ដើម្បីទទួលបានមូលនិធិឥណទានឥតសំណង។ កិច្ចសន្យានេះ នឹងរួមបញ្ចូលនូវលក្ខខណ្ឌនិងខចែងនៃឥណទានឥតសំណងនេះ។
- អ្នកដែលទទួលបានការឧបត្ថម្ភ អាចធ្វើការគ្រប់គ្រងមូលនិធិឥណទានឥតសំណងដោយខ្លួនឯង ឬប្រើប្រាស់ភ្នាក់ងារសារពើពន្ធ។ ថ្លៃភ្នាក់ងាសារពើពន្ធ អាចត្រូវបានគិតថ្លៃពីប្រាក់ឥណទានឥតសំណង ឬអនុវត្តចំពោះវិភាគទានបន្ទ័រ។ អ្នកទទួលបានការឧបត្ថម្ភ ដែលជ្រើសរើសមិនប្រើប្រាស់ភ្នាក់ងារសារពើពន្ធ ត្រូវផ្តល់នូវលេខសម្គាល់ពន្ធរបស់ខ្លួន និងអនុវត្តតាមតម្រូវការរបស់រដ្ឋបាលហូតពន្ធដា។
- ឥណទានឥតសំណង នឹងធ្វើការទូទាត់សងទៅលើការចំណាយនានាណាដែលកើតឡើងបន្ទាប់អំពីកិច្ចសន្យាដែលបានចុះហត្ថលេខាប៉ុណ្ណោះ។

**ភ្នាក់ងារពន្ធ៖**

- អ្នកដាក់ពាក្យស្នើសុំ អាចជ្រើសរើសធ្វើការងារតាមរយៈភ្នាក់ងារពន្ធ ដែលមានទំនួលខុសត្រូវក្នុងការទទួល និងគ្រប់គ្រងមូលនិធិឥណទានឥតសំណងសម្រាប់គម្រោងនោះ។
- អ្នកដាក់ពាក្យស្នើសុំ មានទំនួលខុសត្រូវក្នុងការកំណត់អត្តសញ្ញាណភ្នាក់ងារពន្ធរបស់ខ្លួនផ្ទាល់ និងធ្វើការបញ្ជាក់ថា ភ្នាក់ងារពន្ធនោះ មានអាជ្ញាប័ណ្ណអាជីវកម្មរដ្ឋវ៉ាស៊ីនតោន និងអាជ្ញាប័ណ្ណទីក្រុង Seattle ក្នុងពេលបច្ចុប្បន្ននេះ។
- ភ្នាក់ងារពន្ធ អាចគិតថ្លៃសេវារហូតដល់ 10% នៃប្រាក់ឥណទានឥណសំណងដែលទទួលបាន។ អ្នកអាចរួមបញ្ចូលប្រាក់ថ្លៃសេវានេះទៅក្នុងកញ្ចប់ថវិកាគម្រោងបាន។

**ការបង់ប្រាក់៖**

អ្នកទទួលបានការឧបត្ថម្ភ នឹងប្រគល់នូវវិក្កយបត្រប្រចាំខែ ឬប្រចាំត្រីមាសសម្រាប់ថ្លៃចំណាយពាក់ព័ន្ធនឹងគម្រោង។ SPU នឹងផ្ញើសំបុត្រប្រៃសនីយ៍នៃមូលប្បទានបត្រទូទាត់ប្រាក់ក្នុងរយៈពេលបួនសប្តាហ៍បន្ទាប់ពីទទួលបានវិក្កយបត្រ។ ការបង់ប្រាក់ នឹងត្រូវពន្យារពេល ប្រសិនបើវិក្កយបត្រ មិនទាន់បានបញ្ចប់សព្វគ្រប់ ឬបាត់របាយការណ៍ ឬឯកសារតម្រូវមួយចំនួន។

**ការផ្ញើរបាយការណ៍៖**

- អ្នកដែលទទួលបានការឧបត្ថម្ភ តម្រូវឲ្យប្រគល់ជូននូវរបាយការណ៍វឌ្ឍនភាពការងារ ជាមួយនឹងវិក្កយបត្រនីមួយៗ។
- មុនពេលទទួលបានការបង់ប្រាក់ឥណទានឥតសំណង ចុងក្រោយ អ្នកទទួលបានការឧបត្ថម្ភ ត្រូវប្រគល់ជូននូវរបាយការណ៍ចុងក្រោយដែលចែករំលែកពីលទ្ធផល និងមេរៀនដែលរៀនសូត្រពីគម្រោងនោះ។ របាយការណ៍ត្រូវចុះផ្សាយនៅលើគេហទំព័ររបស់ SPU។

## ទំនាក់ទំនងមកកាន់យើង

ទាក់ទងទៅ wastefreegrants@seattle.gov ឬ (206) 684-7868 សម្រាប់ជំនួយជាភាសាអង់គ្លេស ឬភាសាដែលមិនបានរៀបរាប់នៅផ្នែកខាងក្រោម។

សម្រាប់ជំនួយជាភាសាខាងក្រោមនេះ សូមទំនាក់ទំនងដៃគូរបស់យើង ECOSS តាមរយៈ info@ecoss.org ឬ (206) 767-0432 ext. 1009. សូមផ្ញើសារទុក ហើយគេនឹងទូរសព្ទទៅអ្នកវិញ។

- អារ៉ាប់
- ខ្មែរ
- ចិនទីជីវ
- អេស្ប៉ាញ
- វៀតណាម
- ចិនកាតាំង
- កូរ៉េ
- សូម៉ាលី
- ទីហ្គ្រីនយ៉ា